ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 31-Oct-2012, 11:49
CMS/CFO: Krystal THOMPSON

# លិខិតលះបង់ មានដែនកំណត់

## លិខិតលះបង់សិទ្ធិមានវត្តមាននៅអំឡុងពេលនៃកិច្ចដំណើរការសវនាការរបស់លោក អៀង សារី

អនុលោមតាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៥ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. មាត្រា ១២(១) នៃកិច្ចព្រមព្រៀង វិធាន ៨១(១) នៃវិធានផ្ទៃក្នុង និង មាត្រា ១៤(១) និង ១៤ (៣)(ឃ) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ ខ្ញុំបាទ **អៀង សារី** មានសិទ្ធិទទួលការជំនុំជម្រះក្តីនៅចំពោះវត្តមានរបស់ខ្ញុំ។ ខ្ញុំដឹងថា អនុលោមតាមវិធាន ៨១(៤) និង (៥) ខ្ញុំអាចលះបង់សិទ្ធិមានវត្តមាននៅពេលជំនុំជម្រះក្តី និង នៅក្នុងសវនាការដទៃៗទៀតរបស់ អ.វ.ត.ក. បាន។ តាមរយៈនេះ ខ្ញុំសុំបញ្ជាក់ថា ៖

១. បច្ចុប្បន្ននេះ ខ្ញុំត្រូវបានតំណាងដោយក្រុមមេធាវីការពារក្តី។

២. ខ្ញុំបានទទួលដំណឹង និង យល់ដឹងអំពីបទចោទប្រកាន់មកលើរូបខ្ញុំ។

៣. ខ្ញុំបានទទួលដំណឹងអំពីទីកន្លែង និង កាលបរិច្ឆេទប្រមាណទុកសម្រាប់សវនាការរបស់ខ្ញុំ។

៤. ខ្ញុំបានដឹងអំពីសិទ្ធិមានវត្តមានរបស់ខ្ញុំនៅក្នុងពេលជំនុំជម្រះក្តី និង នៅក្នុងសវនាការដទៃៗទៀតរបស់ អ.វ.ត.ក.។

៥. ខ្ញុំដឹងថាតុលាការតម្រូវឲ្យមានវត្តមានរបស់ខ្ញុំនៅក្នុងពេលជំនុំជម្រះក្តី លើកលែងតែករណីដូចមានចែងក្នុងវិធាន ៨១។

ដោយការយល់ដឹងពេញលេញអំពីដំណើរការនីតិវិធីប្រឆាំងនឹងរូបខ្ញុំ និង អំពីសិទ្ធិទាំងឡាយរបស់ខ្ញុំ ដូចបានថ្លែងខាងលើ ខ្ញុំ ដោយស្ម័គ្រចិត្ត ដោយការយល់ដឹង និង ដោយឥតមន្ទិលសង្ស័យ សុំលះបង់សិទ្ធមានវត្តមាននៅក្នុងដំណើរការនីតិវិធីស្តាប់សក្ខីកម្មសាក្សីទាំងឡាយដូចតទៅ គឺ ដើមបណ្តឹងរដ្ឋប្បវេណី **TCCP-213** ដើមបណ្តឹងរដ្ឋប្បវេណី **TCCP-9** ដើមបណ្តឹងរដ្ឋប្បវេណី **TCCP-35** ដើមបណ្តឹងរដ្ឋប្បវេណី **TCCP-59** ដើមបណ្តឹងរដ្ឋប្បវេណី **TCCP-82** ដើមបណ្តឹងរដ្ឋប្បវេណី **TCCP-105** ដើមបណ្តឹងរដ្ឋប្បវេណី **TCCP-108** ដើមបណ្តឹងរដ្ឋប្បវេណី **TCCP-187** ដើមបណ្តឹងរដ្ឋប្បវេណី **TCCP-188** ដើមបណ្តឹងរដ្ឋប្បវេណី **TCCP-54** ដើមបណ្តឹងរដ្ឋប្បវេណី **TCCP-62** ដើមបណ្តឹងរដ្ឋប្បវេណី **TCCP-117** ដើមបណ្តឹងរដ្ឋប្បវេណី **TCCP-150** ដើមបណ្តឹងរដ្ឋប្បវេណី **TCCP-170** ។ ទោះជាយ៉ាងនេះក្តី ខ្ញុំរក្សាសិទ្ធិដកហូតវិញនូវការលះបង់សិទ្ធិនេះ ក្នុងករណីមានអ្នកណាក្នុងចំណោមសាក្សីទាំងនេះ នៅអំឡុងដំណើរការស្តាប់សក្ខីកម្មរបស់ពួកគេ ប្រែជាចូលពាក់ព័ន្ធនឹងផ្នែកនានាដែលមិនអាចប្រមើលមើលទុកជាមុន

បាន ឬ ផ្នែកនានាដែលស្តែងយ៉ាងច្បាស់ពីកំណត់ហេតុស្តាប់ចម្លើយរបស់ពួកគេ ហើយចាប់ផ្តើមធ្វើសក្ខីកម្ម ទៅលើផ្នែកដែលពាក់ព័ន្ធនឹងខ្ញុំវិញ។

ខ្ញុំ **<u>មិន</u>** លះបង់សិទ្ធិមានរបស់ខ្ញុំនៅក្នុងអំឡុងពេលផ្តល់សក្ខីកម្ម ធ្វើឡើងដោយសាក្សីដទៃទៀតដែលបានគ្រោងនឹងមកបង្ហាញខ្លួននៅក្នុងសំណុំរឿង ០០២/០១ ឬ សាក្សីដទៃទៀតដែលអាចឆ្លើយដាក់បន្ទុកមកលើខ្ញុំ ទោះដោយផ្ទាល់ ឬ ដោយប្រយោលក្តី ឬ អំពើ ឬ បទល្មើសនានាដែលចោទប្រកាន់ចំពោះខ្ញុំនៅក្នុងដីកាដំណោះស្រាយឡើយ។ លើសពីនេះទៅទៀត ក្នុងការធ្វើដូច្នេះ ក៏ខ្ញុំ **<u>មិន</u>** លះបង់សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ជាសារវ័ន្តដទៃៗទៀតរបស់ខ្ញុំនោះទេ ដែលរួមមានការធានាជាអប្បបរមាដូចតទៅនេះ ៖ សិទ្ធិការពារក្តីដោយមេធាវីរបស់ខ្ញុំ សិទ្ធិមានពេលវេលា និង មធ្យោបាយគ្រប់គ្រាន់ សម្រាប់ត្រៀមរៀបចំកិច្ចការពារក្តី សិទ្ធិសួរដេញដោលសាក្សី ឬ សិទ្ធិបានសួរដេញដោលសាក្សីដែលដាក់បន្ទុកមកលើរូបខ្ញុំ និងសិទ្ធិបានការចូលរួមរបស់សាក្សីសម្រាប់រូបខ្ញុំ ឬ សិទ្ធិដទៃៗទៀតដែលត្រូវបានការពារដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីការបង្កើត អ.វ.ត.ក. កិច្ចព្រមព្រៀង និង កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ សហមេធាវីការពារក្តីរបស់ខ្ញុំនឹងមានវត្តមាននៅក្នុងពេលសវនាការ ដើម្បីធានាឲ្យមានការអនុវត្តដោយប្រសិទ្ធភាពនូវសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ខ្ញុំ។ ខ្ញុំសុំរក្សាសិទ្ធិដើម្បីត្រឡប់មកចូលរួមក្នុងកិច្ចដំណើរការនីតិវិធីវិញនៅពេលណាមួយ ដែលចាប់ពីពេលនោះមក លិខិតលះបង់សិទ្ធិនេះនឹងលែងមានសុពលភាពទៀតហើយ។ ខ្ញុំដឹងថា ដោយការលះបង់សិទ្ធិរបស់ខ្ញុំនេះ ខ្ញុំក៏នឹងត្រូវលះបង់សិទ្ធិក្នុងការជំទាស់ថា ការជំនុំជម្រះក្តីរបស់ខ្ញុំគ្មានយុត្តិធម៌ដោយសារតែអវត្តមានរបស់ខ្ញុំ សម្រាប់រយៈពេលនៃការលះបង់សិទ្ធិនេះមានសុពលភាព។

ធ្វើនៅ ភ្នំពេញ រាជធានីនៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១២

ស្នាមមេដៃ



**អៀង សារី** / សំណុំរឿង ០០២